Australian Government
Department of Social Services



# ការរំលោភបំពានខាងផ្លូវភេទ

## នៅប្រទេសអូស្ត្រាលី ការរំលោភបំពានខាងផ្លូវភេទទៅលើអ្នកណាម្នាក់ គឺជាការប្រឆាំងនឹងច្បាប់

ជនណាដែលប្រព្រឹត្តអំពើរំលោភបំពានខាងផ្លូវភេទ អាចជាប់ពន្ធនាគារ  ទោះបីអ្នកនោះជាបុរស ឬស្ត្រីក៏ដោយ។

ប្រសិនបើអ្នក ឬជនណាម្នាក់ដែលអ្នកស្គាល់ស្ថិតនៅក្នុងសភាពគ្រោះថ្នាក់ សូមទូរស័ព្ទទៅប៉ូលីសលេខ **000**។
ប៉ូលីសនៅប្រទេសអូស្ត្រាលីមានសុវត្ថិភាព ហើយអាចទុកចិត្តបាន។

សម្រាប់ការប្រឹក្សាយោបល់ និងការផ្តត់ផ្គង់ជាសម្ងាត់ ហើយឥតគិតថ្លៃ សូមទូរស័ព្ទ 1800 RESPECT លេខ
**1800 737 732**។

ប្រសិនបើអ្នកត្រូវការអ្នកបកប្រែភាសាដោយឥតគិតថ្លៃ សូមទូរស័ព្ទលេខ **131 450**។

## នៅក្នុងស្ថានភាពបែបណាក៏ដោយ រដ្ឋាភិបាលអូស្ត្រាលី មិនអត់ឱនចំពោះការចាប់រំលោភឡើយ

ការរំលោភបំពានខាងផ្លូវភេទគឺជាអំពើប្រព្រឹត្តទៅលើជនឯទៀតដោយគ្មានការយល់ព្រមអំពីគេ។ ការរំលោភបំពានខាងផ្លូវភេទអាចរាប់បញ្ចូលទាំង៖

- ការបង្ខំជនណាម្នាក់ឲ្យរួមភេទ ឬធ្វើសកម្មភាពរួមភេទ
- ការបង្ខំជនណាម្នាក់ឲ្យមើលរឿងអាសអាភាស ឬ
- ការរួមភេទ ឬធ្វើសកម្មភាពរួមភេទជាមួយកុមារ។

ការរំលោភបំពានខាងផ្លូវភេទចំពោះដៃគូ ប្តី ឬប្រពន្ធ ឬសមាជិកក្រុមគ្រួសារណាម្នាក់ ក៏ជាការប្រឆាំងនឹងច្បាប់ដែរ។

## ស្ត្រីមានសិទ្ធិដូចបុរសដែរ

ច្បាប់ប្រទេសអូស្ត្រាលីផ្តល់សិទ្ធិឲ្យស្មើៗគ្នាចំពោះបុរស និងស្ត្រី។

ជនគ្រប់រូបមានសិទ្ធិរស់នៅដោយគ្មានអំពើហិង្សានៅក្នុងទំនាក់ទំនង និងសហគមន៍ដោយសប្បាយរីករាយ។ ស្ត្រីមិនបាច់ទ្រាំទទួលរងនូវការប្រព្រឹត្តមិនគប្បី និងការធ្វើទុក្ខទោសទេ។

## មានសេវាយល់ដឹងពីវប្បធម៌នៅក្នុងប្រទេសអូស្ត្រាលីដែលអាចជួយបាន

**1800 RESPECT** គឺជាសេវាផ្តល់ការប្រឹក្សាអំពីការរំលោភបំពានខាងផ្លូវភេទ អំពើហិង្សាតាមផ្ទះ និងក្នុងគ្រួសារ ទូទាំងប្រទេសរបស់ប្រទេសអូស្ត្រាលី ។ សេវានេះផ្តល់ព័ត៌មាន និងប្រឹក្សាតាមអ៊ីនធើណិត និងទូរស័ព្ទដោយសម្ងាត់ ហើយឥតគិតថ្លៃ។ អ្នកផ្តល់ការប្រឹក្សានឹងស្តាប់អ្នក ឆ្លើយសំណួរ និងអាចបញ្ជូនអ្នកទៅកាន់សេវាជំនួយផ្សេងៗទៀតនៅតាមតំបន់ដែលអ្នករស់នៅ។

សូមទូរស័ព្ទលេខ **1800 737 732** ឬបើកចូលវិបសាយរបស់ 1800 RESPECT នៅត្រង់ **www.1800RESPECT.org.au**។

## តើអ្នកត្រូវការអ្នកបកប្រែភាសាឬទេ?

សូមទូរស័ព្ទទៅសេវាបកប្រែភាសាសរសេរ និងនិយាយ(TIS) ដោយឥតគិតថ្លៃ លេខ **131 450**។ TIS អាចជួយអ្នកឲ្យប្រាស្រ័យទាក់ទងជាមួយសេវាផ្សេងៗទៀត។ TIS មិនផ្តល់ការប្រឹក្សាទេ។